Australian Government
Services Australia

KHMER

# Centrepay

**មនុស្សទី 1៖** តើអ្នកបានដឹងទេថា Services Australia មានសេវាកម្មដោយឥតគិតថ្លៃ ដើម្បីជួយអ្នកក្នុងការគ្រប់គ្រង និងបង់វិក្កយបត្ររបស់អ្នក?

**មនុស្សទី 2៖ ទេ តើវាមានឈ្មោះថាអ្វី ហើយវាដំណើរការយ៉ាងដូចម្តេច?**

**មនុស្សទី 1៖** វាហៅថា Centrepay។ វាឥតគិតថ្លៃ និងជាសេវាបង់វិក្កយបត្រដោយស្ម័គ្រចិត្ត។ អ្នកអាចជ្រើសរើសដើម្បីឱ្យកាត់ចំនួនប្រាក់តិចតួចពីការបង់ប្រាក់ Centrelink របស់អ្នក សម្រាប់រៀងរាល់ពីរសប្តាហ៍ដើម្បីបង់វិក្កយបត្ររបស់អ្នក។

**មនុស្សទី 2៖ តើ Centrepay អាចជួយខ្ញុំបានយ៉ាងដូចម្តេច?**

**មនុស្សទី 1៖** Centrepay គឺជាវិធីមួយដ៏អស្ចារ្យដើម្បីគ្រប់គ្រង និងបង់ការចំណាយគ្រួសារជាប្រចាំរបស់អ្នក ដូចជា៖
- ការជួល
- ទូរសព្ទ
- អគ្គិសនី ហ្គាស និងទឹក
- សេវាកម្មផ្នែកវេជ្ជសាស្ត្រ
- ថ្លៃឈ្នួលថែទាំកុមារ
- ថ្លៃឈ្នួលសាលា និងវិក្កយបត្រជួរវេរនៃផ្សេងទៀត។

Centrepay ជួយអ្នកឱ្យបង់វិក្កយបត្ររបស់អ្នកបានទាន់ពេល។ អ្នកសម្រេច៖
- លើវិក្កយបត្រដែលត្រូវបង់តាមរយៈ Centrepay
- ចំនួនប៉ុន្មានដែលត្រូវកាត់ចេញពីការបង់ប្រាក់ Centrelink របស់អ្នកសម្រាប់រៀងរាល់ពីរសប្តាហ៍។

ចំនួនទាបបំផុតដែលអ្នកអាចកាត់បានគឺ 10 ដុល្លា ក្នុងពីរសប្តាហ៍ម្តង។

អ្នកអ្នកប្រើប្រាស់ Centrepay តែសម្រាប់ទំនិញ និងសេវាកម្មនានាដែលបានផ្តល់ដោយអាជីវកម្មនានាដែលបានយល់ព្រមប៉ុណ្ណោះ។

**មនុស្សទី 2៖ តើខ្ញុំអាចស្វែងរកអាជីវកម្មដែលបានយល់ព្រមយ៉ាងដូចម្តេច?**

**មនុស្សទី 1៖** អ្នកអាចប្រើប្រាស់ឧបករណ៍ស្វែងរក **រកអាជីវកម្ម ឬអង្គការ** នៅលើគេហទំព័ររបស់យើងដើម្បីស្វែងរកអាជីវកម្មនានាដែលស្ថិតនៅក្នុងតំបន់របស់អ្នក។ វារាយឈ្មោះអាជីវកម្មនានាដែលបានយល់ព្រមឱ្យប្រើ Centrepay។

ប្រសិនបើអាជីវកម្ម ឬមនុស្សដែលអ្នកចង់បង់ឱ្យមិនមានក្នុងបញ្ជីនេះទេ សូមទាក់ទងពួកគេ។ សួរពួកគេថាតើពួកគេទទួលយកការបង់ប្រាក់ដោយប្រើ Centrepay ឬអត់។ ប្រសិនបើពួកគេទទួលយកទេ ស្នើសុំពួកគេឱ្យពិចារណាចូលរួម។

**មនុស្សទី 2៖ តើខ្ញុំអាចរៀបចំការកាត់ទុកតាម Centrepay យ៉ាងដូចម្តេច?**

**មនុស្សទី 1៖** អ្នកអាចចាប់ផ្តើម ផ្លាស់ប្តូរ ឬបញ្ឈប់ការកាត់ទុកតាម Centrepay នៅពេលណាក៏បានតាមរយៈ៖
- ការស្នើសុំឱ្យអាជីវកម្មដែលអ្នកចង់បង់ រៀបចំវាសម្រាប់អ្នក

- ការប្រើប្រាស់គណនីអនឡាញ Centrelink របស់អ្នក តាមរយៈ myGov
- ការប្រើប្រាស់ កម្មវិធី Express Plus Centrelink app នៅលើឧបករណ៍ចល័តរបស់អ្នក
- ការចូលទៅទស្សនា មជ្ឈមណ្ឌលសេវាកម្ម
- ការហៅទូរសព្ទមកយើងតាមលេខ **131 202** ដើម្បីនិយាយជាមួយអ្នកណាម្នាក់ជាភាសារបស់អ្នក។

**មនុស្សទី 2៖ តើខ្ញុំអាចស្វែងយល់បន្ថែមអំពី Centrepay នៅឯណា?**

**មនុស្សទី1៖** អ្នកអាចស្វែងយល់បន្ថែមជាភាសាអង់គ្លេសនៅឯ **servicesaustralia.gov.au/centrepay** ឬហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយអ្នកណាម្នាក់ជាភាសារបស់អ្នក។ម្តងទៀតលេខនោះគឺ – **131 202**។

ការគិតថ្លៃហៅទូរសព្ទអាចប្រែប្រួលទៅតាមអ្នកផ្តល់សេវាទូរសព្ទរបស់អ្នក។ អាចមានការគិតថ្លៃហៅទូរសព្ទខ្ពស់ជាងពីទូរសព្ទសាធារណៈ និងទូរសព្ទដៃ។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# Centrepay

**Person 1:** Did you know Services Australia has a free service to help you manage and pay your bills?

**Person 2: No, what is it called and how does it work?**

**Person 1:** It is called Centrepay. It is a free and voluntary bill paying service. You can choose to have small amounts of money deducted from your Centrelink payments each fortnight to pay your bills.

**Person 2: How can Centrepay help me?**

**Person 1:** Centrepay is a great way to manage and pay your regular household expenses, like:

- rent
- telephone
- electricity, gas and water
- medical services
- child care fees
- school fees, and many other bills.

Centrepay helps you pay your bills on time. You decide:

- the bills to pay through Centrepay
- how much to deduct from your Centrelink payments each fortnight.

The lowest amount you can deduct is $10 per fortnight.

You can only use Centrepay for goods and services provided by approved businesses.

**Person 2: How do I find an approved business?**

**Person 1:** You can use the **find a business or organisation** search tool on our website to search for businesses in your area. It lists businesses approved to use Centrepay.

If a business or person you want to pay is not on the list, contact them. Ask them if they accept payments using Centrepay. If they do not, ask them to consider joining.

**Person 2: How do I set up a Centrepay deduction?**

**Person 1:** You can start, change, check or stop a Centrepay deduction at any time by:

- asking the business you want to pay, to set it up for you
- using your Centrelink online account through myGov
- using the Express Plus Centrelink app on your mobile device
- visiting a service centre
- calling us on **131 202** to speak to someone in your language.

**Person 2: Where can I find out more about Centrepay?**

**Person 1:** You can find out more in English at **servicesaustralia.gov.au/centrepay** or call **131 202** to speak to someone in your language. That number again – **131 202**.

Call charges may vary depending on the telephone service provider. There may be higher call charges from public telephones and mobile phones.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.